ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ០៤៧/សាណ.១៧/អអក

ភ្នំពេញ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណ របស់លោកស្រី នៅ សុភា ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃឃុំឈើកាច់ និងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅឃុំឈើកាច់ និងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម (ផលិតកម្ម និងចែកចាយ) ឲ្យលោកស្រី នៅ សុភា ធ្វើសេវាកម្មអគ្គិសនីនៅឃុំឈើកាច់ និងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ពេលនេះអាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យលោកស្រី នៅ សុភា ទិញអគ្គិសនីពីអគ្គិសនីកម្ពុជា មកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មរបស់លោកស្រី នៅ សុភា លែងត្រូវការមធ្យោបាយផលិតកម្មទៀតហើយ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី នៅ សុភា ដោយប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យ ផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចសម្រាប់លោកស្រី នៅ សុភា ដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចនៅ..........................................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅឃុំឈើកាច់ និងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី នៅ សុភា អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **" អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ "** ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**ចាន់ ឌី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,

**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្តីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី៤
## លើឯកសារអាជ្ញាបណ្ណលេខ ២៦៧ ឯអ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់លោកស្រី នៅ សុភា ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃឃុំឈើកាច់ និងឃុំជើងភ្នំ ស្រុកបាភ្នំ ខេត្តព្រៃវែង

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយ

**DECISION ON THE FOURTH REVISION**

TO THE LICENSE DOCUMENT No.267 LD DATED DECEMBER 25, 2009 OF MRS. NOV SOPHEA FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF KHUM CHHEUR KACH AND KHUM CHEUNG PHNOM, BAPHNOM DISTRICT, PREY VENG PROVINCE

**FOR CHANGING THE TYPE OF LICENSE**

**FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE**

ថ្ងៃទី ខែ ឆ្នាំ២០១៧

.. .., 2017